## ជំពូក ២

## អវសានប្បញ្ញត្តិ

**មាត្រា ៣ ._** បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ ._** អនុក្រឹត្យនេះ មានគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**មាត្រា ៥ ._** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីមហាផ្ទៃ រដ្ឋមន្ត្រីកសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និង នីតិសម្បទា ព្រមទាំងរដ្ឋមន្ត្រីនៃបណ្តាក្រសួង និងស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

រាជធានីភ្នំពេញ,ថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ៤៣ អនក្រ.បក

## ស្តីពីការបង្កើតក្រុមប្រឹក្សារំសាយ

## កងកំលាំងប្រដាប់អាវុធ

***

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- តាមសំណើរបស់ប្រធាន ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

## សំរេច

## ជំពូក ១

## ក្រុមប្រឹក្សារំសាយកងប្រដាប់អាវុធ

មាត្រា ១ ._ ត្រូវបានបង្កើតក្រុមប្រឹក្សារំសាយកងប្រដាប់អាវុធ ដែលមានស្វយ័តភាពរដ្ឋបាល ។ ក្រុមប្រឹក្សារំសាយកងប្រដាប់អាវុធ មានបេសកកម្មអនុលោមទៅតាមការតំរង់ទិស និង ស្ថិតនៅក្រោមការត្រួតពិនិត្យមើលរបស់ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ក្នុងការផ្តួចផ្តើម និង ជំរុញការដោះស្រាយបញ្ហារំសាយកងប្រដាប់អាវុធ ព្រមទាំងដើរតួជានិយ័តករ និង ជាតំណាងជំរុញដោយមានការទទួលខុសត្រូវ និង មានការយកចិត្តទុកដាក់ខ្ពស់លើលទ្ធផលជាក់ស្តែង ។

មាត្រា ២ ._ ក្រុមប្រឹក្សារំសាយកងប្រដាប់អាវុធ មានសមាសភាពដូចតទៅ ៖

| | |
|---|---|
| -ឯកឧត្តម សុខ អាន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| -ឯកឧត្តម ឧត្តមសេនីយ៍ឯក ចាយ សាំងយុន រដ្ឋលេខាធិការក្រសួងការពារជាតិ | អនុប្រធាន |
| -ឯកឧត្តម ឧត្តមសេនីយឯក មាស សុផា អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ | អនុប្រធាន |
| -ឯកឧត្តម អ៊ុក រ៉ាប៊ុន រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| -ឯកឧត្តម ព្រុំ សុខា រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | សមាជិក |
| -ឯកឧត្តម លី ធុច រដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| -ឯកឧត្តម នឹម ថូត រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា | សមាជិក |
| -លោកជំទាវ យូ អយ រដ្ឋលេខាធិការ ក្រសួងកិច្ចការនារីនិងអតីតយុទ្ធជន | សមាជិក |
| -ឯកឧត្តម ចាន់ តុងអ៊ីវ រដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ | សមាជិក |
| -ឯកឧត្តម នូ សាំងខន រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ | សមាជិក |
| -ឯកឧត្តម ម៉ុល រឿប ទីប្រឹក្សា សម្តេច នាយករដ្ឋមន្ត្រី ទទួលបន្ទុកការងារយោធា | សមាជិក |
| -ឯកឧត្តម ស្វាយ ស៊ីថា អនុរដ្ឋលេខាធិការ អមទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក- |
| ឯកឧត្តមឧត្តមសេនិយទោ តួង ស៊ីផាន នាយសេនាធិការរងចំរុះនៃអគ្គបញ្ជាការ | សមាជិក |

## ជំពូក ២

## អវសានប្បញ្ញត្តិ

មាត្រា ៣ ._ បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ ._ អនុក្រឹត្យនេះ មានគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

មាត្រា ៥ ._ រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួង

សង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង នីតិសម្បទា ព្រមទាំងរដ្ឋមន្ត្រីនៃបណ្តាក្រសួងនិងស្ថាប័ន ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

រាជធានីភ្នំពេញ,ថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

## អនុក្រឹត្យលេខ ១៣៣ អនក្រ.តត
## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៧៦/អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៨ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណូមពរការងារចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## សំរេច

មាត្រា ១ ._ តែងតាំងលោក អ៊ិន សុផល្លែត ជា ជំនួយការសម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជាមានឋានៈស្មើ អគ្គនាយករង ។

មាត្រា ២ ._ បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី០១ ខែឧសភា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន